មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
# សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

www.cchrcambodia.org
លេខ ១៣៖ ខែសីហា ឆ្នាំ ២០២១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានធ្វើការសង្កេតការណ៍សវនាការ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌនៅតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តការជំនុំជម្រះដោយយុត្តិធម៌តាមបទដ្ឋានជាតិ និងអន្តរជាតិចាប់ពីឆ្នាំ២០០៩ និងបានសង្កេតសវនាការនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញចាប់តាំងពីខែមីនា ឆ្នាំ២០១៣។ ព្រឹត្តិបត្រព័ត៌មាននេះ គឺជាផ្នែកនៃការចេញផ្សាយជាស៊េរី ដែលវិភាគលើរបកគំហើញរបស់យើង។ ព្រឹត្តិបត្រព័ត៌មាននេះ ផ្តោតជាពិសេសលើសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ សាធារណជនអាចស្វែងរកទិន្នន័យដែលបានប្រមូលទាំងអស់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់យើង។

## សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសគឺជាសិទ្ធិមូលដ្ឋាន

ទាំងច្បាប់ជាតិ និងអន្តរជាតិទទួលស្គាល់ការសន្មតទុកជាមុនថាគ្មានទោសគឺជាសិទ្ធិមូលដ្ឋាន។ ការអនុវត្តគោលការណ៍នេះមិនត្រឹមតែជាលក្ខខណ្ឌចាំបាច់ ដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ ប៉ុន្តែក៏ជាឧបករណ៍គ្រឹះដើម្បីជំរុញការជឿជាក់លើនីតិរដ្ឋផងដែរ។ មាត្រា ១១(១) នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") ធានាសិទ្ធិត្រូវបានសន្មតថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ។ មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាដែលកម្ពុជាជារដ្ឋភាគី និងក៏ដូចជា ស.ស.ស.ម ដែរ ដែលត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិតាមរយៈរដ្ឋធម្មនុញ្ញចែងថា "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានបង្ហាញស្របតាមច្បាប់"។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។

សិទ្ធិនេះត្រូវបានចង្អុលបង្ហាញក្នុងរបៀបផ្សេងៗគ្នាជាច្រើន។ ឧទាហរណ៍ សិទ្ធិនេះដាក់បន្ទុកលើអយ្យការឱ្យផ្តល់ភស្តុតាងពីបទចោទរបស់ខ្លួន និងធានាថាគ្មានពិរុទ្ធភាពណាមួយអាចត្រូវបានសន្មតទុកជាមុននោះទេ វៀរលែងតែបទចោទត្រូវបានផ្តល់ភស្តុតាងលើសពីវិមតិសង្ស័យ។[1] សិទ្ធិនេះក៏តម្រូវឱ្យអាជ្ញាធរសាធារណៈទាំងអស់រួមមាន ព្រះរាជអាជ្ញា នគរបាល និងមន្ត្រីរដ្ឋាភិបាល ជៀសវាងធ្វើឱ្យមានផលប៉ះពាល់លើលទ្ធផលនៃការជំនុំ

> **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**
>
> *"ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។"*
>
> **មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**
>
> *"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។"*

ជម្រះតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។[2] សិទ្ធិនេះរួមបញ្ចូលទាំងភារកិច្ចដើម្បីធានាថា ប្រព័ន្ធផ្សព្វផ្សាយមិនត្រូវធ្វើឱ្យអន្តរាយដល់ភាពត្រឹមត្រូវយុត្តិធម៌នៃសវនាការព្រហ្មទណ្ឌតាមរយៈការធ្វើបុរេវិនិច្ឆ័យ ឬឥទ្ធិពលលើលទ្ធផលនៃការជំនុំជម្រះនេះ។ ក្នុងន័យជាក់ស្តែង ការសន្មតទុកជាមុនថាគ្មានទោសក៏ការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរូបភាព មានសេចក្តីថ្លៃថ្នូរក្នុងនាមជាពលរដ្ឋធម្មតា និងគ្មានទោសពៃរ៍។ ហេតុដូចនោះ ជនជាប់ចោទពុំត្រូវបានដាក់ខ្នោះ ដាក់ក្នុងទ្រុង ឬតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានពន្ធនាគារឡើយ[3] ហើយចៅក្រមត្រូវតែប្រាប់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀម និងពន្យល់អំពីសិទ្ធិនេះដល់ពួកគេថែមទៀត។

## សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសក្នុងការអនុវត្តជាក់ស្តែង

**ឯកសណ្ឋានពន្ធនាគារ**

នៅពេលដែលជនជាប់ចោទចូលខ្លួនក្នុងសវនាការក្នុងសម្លៀកបំពាក់ជាទណ្ឌិត[4] ដែលនេះទាក់ទិននឹងការយល់ឃើញជាមុនថា ជនជាប់ចោទជាអ្នកមានទោសនិងនាំឱ្យជះឥទ្ធិពល (ដោយចេតនា ឬអចេតនា) ដល់ការវិនិច្ឆ័យរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រម ហើយអាចប៉ះពាល់ដល់ដំណើរការនីតិវិធីនិងចុងក្រោយបង្អស់គឺលទ្ធផលនៃរឿងក្តី។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានរកឃើញថា *"ការតម្រូវឱ្យអ្នកជាប់ឃុំបណ្តោះអាសន្ន និងទណ្ឌិតត្រូវតែពាក់អាវដែលបង្ហាញពីកន្លែងជាប់ឃុំខ្លួនរបស់ពួកគេ បង្ហាញពីការប្រព្រឹត្តដែលប៉ះពាល់ដល់កិត្តិយសរបស់ពួក*

[1] គណៈកម្មាធិការសិទ្ធិមនុស្ស 'សេចក្តីពន្យល់ទូទៅលេខ៣២' (២០០៧) UN Doc CCPR/C/GC/32 វាក្យខណ្ឌ ៣០។

[2] ដូចយោងខាងលើ។

[3] ដូចយោងខាងលើ។

[4] នៅក្នុងព្រឹត្តិបត្រព័ត៌មាននេះ "ទណ្ឌិត" សំដៅដល់ជនទាំងឡាយណា ដែលត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាព និងសេចក្តីសម្រេចបានចូលជាស្ថាពរហើយ បន្ទាប់ពីអស់សិទ្ធិប្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់។ "ជនជាប់ចោទ" សំដៅដល់ជនទាំងឡាយណា ដែលប្រឈមនឹងបទចោទព្រហ្មទណ្ឌដែលមិនទាន់ទទួលបានសេចក្តីសម្រេចជាស្ថាពរនៅឡើយ ។

CC BY NC SA

*គេដែរ* និងថាការតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានបែបនេះ នៅអំឡុងពេលជំនុំជម្រះអាចរំលោភបំពានលើសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។[5]

វិធាន ១១៥ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមា



**ម.ស.ម.ក ជនជាប់ចោទក្នុងសំលៀកបំពាក់ទណ្ឌិត**

សម្រាប់ការអនុវត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺឡា) អនុម័តដោយមហាសន្និបាត ឆ្នាំ២០១៥ ចែងថា *"ត្រូវអនុញ្ញាតឱ្យជនជាប់ឃុំប្រើសម្លៀកបំពាក់របស់ពួកគេ ក្នុងសម្លៀកបំពាក់ស្អាតបាត និងសមរម្យ។ ប្រសិនបើគេត្រូវប្រើសម្លៀកបំពាក់របស់ពន្ធនាគារ សម្លៀកបំពាក់ទាំងនេះមិនត្រូវឱ្យដូចគ្នានឹងជនជាប់ឃុំដែលតុលាការបានកាត់ទោសស្ថាពររួចហើយនោះទេ"*។ ខណៈដែលវិធាននេះមិនបានចងជាកាតព្វកិច្ចផ្លូវច្បាប់លើកម្ពុជា ឬសមាជិកដទៃទៀតនៃ អ.ប.ស ក៏ដោយ វិធាននេះតំណាងឱ្យការអនុវត្តដ៏ល្អបំផុតដែលអន្តរជាតិទទួលស្គាល់សម្រាប់ការអនុវត្តទៅលើជនជាប់ឃុំ។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេ នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌរហូតដល់តុលាការកាត់ទោសជាស្ថាពរ។

នៅកម្ពុជា ឯកសណ្ឋានរបស់ជនជាប់ឃុំត្រូវបានកំណត់ដោយនីតិវិធីពន្ធនាគារលេខ៥ របស់ក្រសួងមហាផ្ទៃស្តីពី "ឯកសណ្ឋានជនជាប់ឃុំ និងសម្ភារបរិក្ខារនៅក្នុងបន្ទប់ឃុំឃាំង" ឆ្នាំ២០០៣ ត្រង់ចំណុច ៤(១)៖ "មន្ត្រីទទួលបន្ទុកយកអ្នកទោសចូល ត្រូវធានាថានៅពេលទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ ត្រូវផ្តល់ឱ្យអ្នកទោសនូវឯកសណ្ឋាន និងសម្ភារបរិក្ខារដូចខាងក្រោម៖ អាវអំបោះពណ៌ខៀវ ឆ្នូតសពីរ ខោអំបោះពណ៌ខៀវឆ្នូតសពីរ។" នៅក្នុងប្រកាសឆ្នាំ២០១៣ បានបង្គាប់ថា បុគ្គលដែលតុលាការមិនទាន់បានកាត់ទោស ឬការកាត់ទោសរបស់គេមិនទាន់ចូលជាស្ថាពរ ហើយដែលអ្នកទាំងនេះ ត្រូវអាជ្ញាធរឃុំខ្លួននឹងតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ ខណៈដែលមានការស្វាគមន៍ ចំពោះការកំណត់ផ្សេងគ្នារវាងឯកសណ្ឋានសម្រាប់ទណ្ឌិត និងជនជាប់ឃុំដែលមិនទាន់មានសេចក្តីសម្រេចស្ថាពរក៏ដោយ ដើម្បីធានាថាសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ត្រូវបានគោរពយ៉ាងពេញលេញ ជនជាប់ចោទទាំងអស់ដែលមិនទាន់កាត់ទោសជាស្ថាពរ គួរតែអាចស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេពេលបង្ហាញមុខចំពោះតុលាការ។

ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតការណ៍លើសំណុំរឿងចំនួន២០៣ ទាក់ទងនឹងជនជាប់ចោទចំនួន២៥៥ នាក់ នៅសាលាឧទ្ធរណ៍ភ្នំពេញ។ សំណុំរឿងទាំងអស់នេះទាក់ទងនឹងជនជាប់ចោទ ដែលសាលាដំបូងបានកាត់ទោសរួចហើយ ប៉ុន្តែការកាត់សេចក្តីរបស់ពួកគេ កំពុងស្ថិតនៅក្នុងដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍និងមិនទាន់បានចូលជាស្ថាពរនៅឡើយ។ នៅអំឡុងពេលសង្កេតការណ៍សវនាការនេះ ជនជាប់ចោទចំនួន ៧២ នាក់ បានបង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវ។ ជនជាប់ចោទចំនួន ១៤៩ នាក់ បានបង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានពណ៌ទឹកក្រូចចាស់ ដែលត្រូវបានកំណត់សម្រាប់បុគ្គលដែលសេចក្តីសម្រេចរបស់តុលាការ មិនទាន់ចូលជាស្ថាពរ ឬបង្ហាញខ្លួននៅមុខតុលាការក្នុងសម្លៀកបំពាក់ខ្លួនឯងផ្ទាល់។ ជនជាប់ចោទចំនួន ៣៤ នាក់ មិនមានវត្តមាននៅក្នុងដំណើរការនីតិវិធី




---

[5] UNHRC 'សេចក្តីសង្កេតសន្និដ្ឋាននៃគណៈកម្មាធិការលើរបាយការណ៍បឋមនៃប្រទេសបេនីន' ខែវិច្ឆិកា ២០០៤ UN Doc CCPR/C/82/BEN វាក្យខណ្ឌ ២១។

CC BY NC SA

ឬមួយក៏បានបង្ហាញខ្លួននៅមុខតុលាការក្នុងសម្លៀកបំពាក់ខ្លួនឯងផ្ទាល់ ដោយសារតែពួកគេមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។

ហេតុដូច្នេះ ទិន្នន័យនេះបង្ហាញថា សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ។ ចំនួនជនជាប់ចោទចំនួនជាងមួយភាគបួនបានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវ។ បើទោះជាមានការណែនាំអំពីឯកសណ្ឋានពណ៌ទឹកក្រូចចាស់នេះក៏ដោយ ស្ថានភាពនេះមិនមានភាពប្រសើរនៅឡើយ បើប្រៀបធៀបទៅនឹងការរកឃើញនៅឆ្នាំ២០១៨/២០១៩ ដែល ម.ស.ម.ក បានសង្កេតការណ៍សវនាការលើសំណុំរឿងចំនួន ២៣៩ នៅសាលាឧទ្ធរណ៍ភ្នំពេញចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ដែល ២២% (៧៧ នៃ ៣៥២ នាក់) នៃជនជាប់ចោទបានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវ។

ជនជាប់ចោទ ដែលតុលាការពុំបានទាន់កាត់ទោសជាស្ថាពរ និងបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវ គឺផ្ទុយនឹងវេជ្ជមុន្នុញ [ប្រកាស](#)ឆ្នាំ២០១៣ និងនីតិវិធីពន្ធនាគារលេខ៥។ បញ្ហានេះក៏មិនស្របទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលធានានូវសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងបទដ្ឋានអន្តរជាតិ ដូចជាបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ជាដើម។

**ការវិវឌ្ឍនៃសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស (ឆ្នាំ២០១៦ ដល់ ឆ្នាំ ២០២០)**

ចំនួនជនជាប់ចោទមានវត្តមាននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវមានការកើនឡើងគួរឱ្យកត់សម្គាល់ តាំងពីឆ្នាំ២០១៦។ ទិន្នន័យបង្ហាញថា ជនជាប់ចោទចំនួនត្រឹមតែ ៩% ប៉ុណ្ណោះដែលបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវនៅឆ្នាំ២០១៦-២០១៧ ខណៈដែលជនជាប់ចោទចំនួន ២៨% បានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតពណ៌ខៀវនៅឆ្នាំ២០១៩-២០២០ ដែលជាការបំពានលើសិទ្ធិសន្មតទុកជាមុនថាគ្មានទោសរបស់ជនជាប់ចោទ។




**សិទ្ធិនៅស្ងៀម**

សិទ្ធិនៅស្ងៀមចាក់ឫសនៅក្នុងសិទ្ធិទទួលបានការសន្មតទុកជាមុខថាគ្មានទោស។ ហេតុដូចនេះ ចៅក្រមត្រូវធានាថា ជនជាប់ចោទត្រូវបានប្រាប់គ្រប់គ្រាន់អំពីសិទ្ធិនេះ និងពន្យល់ពីខ្លឹមសារនៃសិទ្ធិនេះផងដែរ។ គួរឱ្យសោកស្ដាយ នៅឆ្នាំ២០១៨-២០១៩ ចៅក្រមសាលាឧទ្ធរណ៍ខកខានក្នុងការប្រាប់ និងពន្យល់សិទ្ធិនៅស្ងៀមដល់ជនជាប់ចោទនៅក្នុងសំណុំរឿងចំនួន ៦៦% ដែលបានសង្កេតការណ៍ដោយ ម.ស.ម.ក និងបានតែប្រាប់សិទ្ធិនេះដល់ជនជាប់ចោទនៅក្នុងសំណុំរឿងចំនួន ២៦% ដោយមិនបានពន្យល់ឡើយ។ ក្នុងឆ្នាំ២០១៩-២០២០ ចៅក្រមសាលាឧទ្ធរណ៍មិនបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមនៅក្នុងសំណុំរឿងចំនួន ២៥,៦% ដែលបានសង្កេតការណ៍ដោយ ម.ស.ម.ក និងបានតែប្រាប់អំពីសិទ្ធិនៅស្ងៀមនេះដល់ជនជាប់ចោទដោយមិនបានពន្យល់នៅក្នុងសំណុំរឿងចំនួន ៣១% ដែលបង្ហាញថាមានភាពប្រសើរឡើង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨-២០១៩។ ទោះបីជាយ៉ាងនេះក្ដី ជាការចាំបាច់ ដែលចៅក្រមត្រូវប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទទាំងអស់ ដើម្បីធានានាការគោរពពេញលេញចំពោះសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស។

**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

ជនជាប់ចោទគ្រប់រូបមានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។ ដូច្នោះ ម.ស.ម.ក ស្នើ៖

- ក្រសួងមហាផ្ទៃគួរតែអនុវត្តតាមការប្រតិបត្តិល្អបំផុតដែលមានលក្ខណៈជាអន្តរជាតិរបស់ អ.វ.ត.ក ដែលអនុញ្ញាតឱ្យជនជាប់ចោទស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេ នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ រហូតដល់សេចក្ដីសម្រេចនៃការកាត់ទោសនោះបានចូលជាស្ថាពរ។
- ក្រសួងមហាផ្ទៃគួរពិនិត្យ និងកែប្រែលិខិតូបករណ៍គតិយុត្ត គោលនយោបាយ និងការអនុវត្តរបស់ខ្លួនកន្លងមកដែលមានស្រាប់ឡើងវិញ ដើម្បីធានាថាស្របតាមបទដ្ឋានអន្តរជាតិ ដែលបានកំណត់ដូចខាងលើ។ ក្នុងអំឡុងពេលមិនទាន់មានការកែសម្រួលបទបញ្ញត្តិថ្មីទេ ក្រសួងមហាផ្ទៃគួរធានាថា ការប្រើប្រាស់ស្លៀកពាក់ឯកសណ្ឋានពន្ធនាគារសម្រាប់ជនជាប់ឃុំ ត្រូវតែស្របតាមជាមួយនឹងបទបញ្ញត្តិដូចបានកំណត់ក្នុងប្រកាសឆ្នាំ២០១៣។

CC BY NC SA

- ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវចេញផ្សាយ និងផ្សព្វផ្សាយគោលការណ៍ណែនាំឱ្យបានច្បាស់លាស់ថាជនជាប់ចោទដែលកំពុងស្ថិតក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ស៊ីវិលធម្មតានៅពេលបង្ហាញខ្លួនក្នុងពេលសវនាការ។
- ចៅក្រមសាលាឧទ្ធរណ៍គួរអនុញ្ញាតឱ្យជនជាប់ចោទដែលត្រូវបាននាំមកតុលាការក្នុងឯកសណ្ឋានជាទណ្ឌិត ស្លៀកសម្លៀកបំពាក់ស៊ីវិលធម្មតារបស់ពួកគេជំនួសវិញនៅពេលសវនាការ។
- ចៅក្រមនៃសាលាឧទ្ធរណ៍គួរតែប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទទាំងអស់។

ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក លេខមុនៗ អាចរកបានតាមគេហទំព័ររបស់ ម.ស.ម.ក (លេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ លេខ៦ លេខ៧ លេខ៨ លេខ៩ លេខ១០ លេខ១១ និង លេខ១២)។ លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០១៨ របាយការណ៍ប្រចាំឆ្នាំ២០១៩ និងរបាយការណ៍ឆ្នាំ២០២០ របស់យើងស្តីពី"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ដែលបានបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ ចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។